**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកោះកុង**
សំណុំរឿងរដ្ឋប្បវេណីលេខ ១៨
ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២
សាលក្រមលេខ ២៦ "ខ"
ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

# ឈ្មោះប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកោះកុង

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោងពីរ និងសាមសិបនាទីរសៀល នៅសាលសវនាការទី១ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៨ ចុះនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដោយមានសមាសភាពចូលរួម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជី**

លោក ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

ដើមចោទ៖ ឈ្មោះ [redacted] សេង កើតឆ្នាំ១៩៦៨ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន [redacted]។

អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖ លោក [redacted] ជាមេធាវី និងសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ៧២៩ [redacted]។

សហចុងចម្លើយ៖ ឈ្មោះ [redacted] សារុន ភេទប្រុស កើតឆ្នាំ១៩៦៤ ជនជាតិខ្មែរ កាន់អត្តសញ្ញាប័ណ្ណលេខ១៨០០០៧៣៣៣ (០១) មានអាសយដ្ឋានបច្ចុប្បន្ន [redacted] និងប្រពន្ធឈ្មោះ [redacted] សុខហ៊ួច ភេទស្រី កើតឆ្នាំ១៩៧៧ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១៨០០០៧៣៣២ (០១) ។

អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ៖ លោក [redacted] អត្តលេខ៥៧០ និងលោកមេធាវី [redacted] អត្តលេខ៧០៧ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា [redacted] ។

## I. អង្គហេតុ និងចំណុចវិវាទ

### ១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ



Scanned with CamScanner

១/ សុំរំលាយលិខិតប្រគល់ និងទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រវាងឈ្មោះ [redacted] សេង និងឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ។

២/ រឹបអូសប្រាក់កក់ពីសហចុងចម្លើយឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច នូវទឹកប្រាក់សរុបចំនួន ២៨,០០០$ (ពីរម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក ឱ្យទៅដើមចោទឈ្មោះ [redacted] សេង ។

៣/ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

២.អង្គហេតុ

កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] សេង ព្រមទាំងឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច បានធ្វើការចុះលិខិតប្រគល់ និងទទួលប្រាក់កក់ចំនួន ២៨០០០$ (ពីរម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក ស្មើនឹង ១០% (ដប់) ភាគរយ នៃចំនួនទឹកប្រាក់ សរុបទាំងអស់ ២៨០០០០$ (ម្ភៃប្រាំបីម៉ឺន) ដុល្លារអាមេរិក ដើម្បីឱ្យឈ្មោះ [redacted] សេង យកទៅរៀបចំឯកសារវាស់វែងនៅកំណត់ព្រំដីឱ្យបានច្បាស់លាស់ ។ ហើយនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០២១ លោកមេឃុំជ្រោយប្រស់ បានចេញលិខិតជូនដំណឹងលេខ ១៥២/០២១ ដោយបានធ្វើការវាស់វែងដីដែលមានទីតាំងស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ។ ហើយនៅក្នុងលិខិតប្រគល់ និងទទួលប្រាក់គ្រង់ ប្រការ១ ចំណុច១.២ នៅពេលដែលគូភាគីត្រូវរៀបចំវាស់វែងដីដែលមានការចូលរួមពី មន្ត្រីសួរិយោដី មន្ត្រីបរិស្ថាន មន្ត្រីមេព្រៃ មន្ត្រីភូមិ ឃុំ និងគណៈកម្មការស្រុក ក្នុងការវាស់វែងនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ហើយនោះឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ត្រូវបង់ប្រាក់ចំនួន១១២០០០$ (ដប់មួយម៉ឺនពីរពាន់) ដុល្លារអាមេរិកបន្ថែមទៀតដើម្បីបង្គ្រប់ ៥០% (ហាសិប) ភាគរយ នៃថ្លៃដីសរុប និងនៅក្នុងប្រការ៣ ករណីប្រធានសក្តិ គឺឈ្មោះ [redacted] សេង បានធ្វើការបំពេញការងារជូនតាមបែបបទរដ្ឋបាល បានរៀបចំធ្វើពាក្យស្នើសុំកាន់កាប់ និងប្រើប្រាស់ដីធ្លីឱ្យឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ប៉ុន្តែបែរជាសហចុងចម្លើយ បានដាក់ពាក្យបណ្តឹងនៅស្នងការនគរបាលជាតិខេត្តកោះកុងថា ខ្លួន (ឈ្មោះ [redacted] សេង) ធ្វើការឆបោកឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ទៅវិញ ។ ម្យ៉ាងទៀតរហូតមកដល់ពេលនេះ សហចុងចម្លើយ មិនបានទូរទាត់ប្រាក់ដែលនៅ ៥០% (ហាសិប) ភាគរយស្មើនឹងចំនួន ១១២០០០$ (ដប់មួយម៉ឺនពីរពាន់) ដុល្លារអាមេរិក មកខ្លួន (ឈ្មោះ [redacted] សេង) នោះទេ ។

ដូច្នេះខ្លួនសុំធ្វើការរំលាយលិខិតប្រគល់ និងទទួលប្រាក់កក់ ចុះនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រវាងខ្លួន (ឈ្មោះ [redacted] សេង) ព្រមទាំងឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ចោល និងសុំរឹបអូសយកប្រាក់កក់ ដែលបានកក់ចំនួន ២៨០០០$ (ពីរម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក ស្មើនឹង១០% (ដប់) ភាគរយនេះ ដោយសហចុងចម្លើយ មិនបានគោរពនូវកាតព្វកិច្ចតាម លិខិតប្រគល់ និងទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។ ម្យ៉ាងទៀត តាមប្រការ៣ នៃលិខិតប្រគល់ និងទទួលប្រាក់កក់ ដែលបាននិយាយដោះស្រាយគ្នា ដោយសន្តិវិធី តែបែរជាសហចុងចម្លើយមិនអនុវត្តន៍កាតព្វកិច្ចហើយមកដាក់ប្តឹងខ្លួន (ឈ្មោះ [redacted] សេង) រឿងព្រហ្មទណ្ឌទៅវិញ ។

៣.ការអះអាងរបស់គូភាគី

ក. ការអះអាងរបស់គូភាគីនៅដំណាក់កាលនីតិវិធីត្រៀមទាញហេតុផលកាល ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង៣រសៀល៖



Scanned with CamScanner

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សេង បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមរក្សាការទាមទារនៅក្នុងពាក្យបណ្តឹង និងអង្គហេតុ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ទុកជាបានការដដែល ។ ខ្លួនសូមបញ្ជាក់ថា មូលហេតុនៃការទាមទារទាំងអស់ ដូចមាននៅក្នុងពាក្យបណ្តឹង នោះគឺ ដោយសារតែភាគីសហចុងចម្លើយ គាត់មិនបានបំពេញកាតព្វកិច្ច នៅក្នុងប្រការ១ ចំណុច១.២ ដោយហេតុថា នៅពេលដែលកូនក្តីរបស់ខ្លួន ធ្វើការចុះវាស់វែងរួចហើយនោះ ភាគីសហចុងចម្លើយ ត្រូវធ្វើការទូទាត់ប្រាក់បន្ថែម ចំនួន ១១២០០០$ (ដប់មួយម៉ឺនពីរពាន់ដុល្លារសហរដ្ឋអាមេរិច) តែភាគីមិនបានប្រគល់ឱ្យទៅតាមកំណត់ នៅក្នុងកិច្ចព្រមព្រៀងនោះទេ ។ ជាក់ស្តែង ខ្លួនសូមបញ្ជាក់បន្ថែមថា ភាគីបានចុះវាស់វែង យ៉ាងពិតប្រាកកដមែន ដូចមានបញ្ជាក់នៅក្នុងលិខិតរបស់អភិបាលនៃរដ្ឋបាលស្រុកកោះកុងលេខ ០៥០/៥១ ស.ជ.ណ ចុះនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ និងលិខិតរបស់ខាងឃុំជ្រោយប្រស់ លេខ ១៥២/០២១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ដែលមាន បញ្ជាក់ស្តីអំពីការចុះពិនិត្យដីមិនទាន់ចុះបញ្ជីដែលមានទំហំ១២ហិកតា ។ ដូចនេះហើយ បានខ្លួនជាមេធាវីសន្និដ្ឋានថា ភាគីសហចុងចម្លើយ មិនបានបំពេញតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះទេ បែរជាមកធ្វើការទាមទារប្រាក់ដែលបានកក់ទៅវិញ ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] សារុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច បានធ្វើសេចក្តីថ្លែងការណ៍តបថា៖ ខ្លួនសូមបដិសេធ ចំពោះការលើកឡើងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ខ្លួនសូមបញ្ជាក់ នូវអង្គហេតុដែលកូនក្តីខ្លួន បានទិញដីពីឈ្មោះ [redacted] សេង ដែលមានប្រពន្ធឈ្មោះ [redacted] ប៉ោហេង ជាសាក្សី ទំហំ១២ហិកតា ។ កូនក្តីខ្លួនបានប្រគល់ប្រាក់ជូនភាគីដើមចោទ ចំនួន ២៨០០០$ (ពីរម៉ឺនប្រាំបីពាន់ដុល្លារសហរដ្ឋអាមេរិច) រួចរាល់ហើយ ប៉ុន្តែនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ នៅពេលដែលកូនក្តីខ្លួន និងភាគីអ្នកលក់ទៅពិនិត្យទីតាំងដី និងបានចុះបានវាស់វែងតាមលិខិតលេខ ០៥៦/២១ ស.ជ.ណ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ របស់សាលាស្រុកកោះកុង ពេលចុះទៅដល់ទីតាំងជាក់ស្តែង ទើបដឹងច្បាស់ថាដីខាងលើនេះ គឺពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្គ្រីនរិចគ្រុប ។ ទោះបីជាពិនិត្យ និងមើលឃើញយ៉ាងច្បាស់ថា ដីនេះពាក់ព័ន្ធនឹងដីសម្បទានរបស់ក្រុមហ៊ុនក៏ដោយ ក៏ភាគីលោក [redacted] សេង និងលោកស្រី [redacted] ចាន់សូម៉ាឡា នៅតែអះអាងថាដីខាងលើ ជាដីរបស់ខ្លួនដដែល ហើយធានាអះអាងថា ធ្វើការកាត់ឆ្វៀល និងបំបែកចេញពីអនុក្រឹត្យរបស់រាជរដ្ឋាបាល ដើម្បីធ្វើការកាត់ឈ្មោះ ឱ្យកូនក្តីខ្លួន ដោយភាគីអ្នកលក់ នៅតែស្នើសុំឱ្យភាគីកូនក្តីខ្លួន បង់ប្រាក់ថ្លៃទិញលក់ចំនួន៤០% បន្ថែមទៀត ដើម្បីខ្លួនយកទៅរត់ការកាត់ឈ្មោះជូនមកភាគីសហចុងចម្លើយ ។ ក្រោយមកទៀតខ្លួនបានដាក់ពាក្យស្នើសុំទៅលោកអភិបាលស្រុកកោះកុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ដើម្បីដឹងព័ត៌មានពាក់ព័ន្ធដីខាងលើឱ្យកាន់តែច្បាស់ ដែលបញ្ជាក់អំពីអត្ថិភាពនៃការកាន់កាប់របស់ឈ្មោះ [redacted] សេង និងលោកស្រី [redacted] ចាន់សូម៉ាឡា លើដីដែលមានទំហំ១២ហិកតា មានទីតាំងស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ។ តើជាដីរបស់ក្រុមហ៊ុន ហ្គ្រីនរិចគ្រុប ឬជាដីរបស់ឈ្មោះ [redacted] សេង និងលោកស្រី [redacted] ចាន់សូម៉ាឡា តាមរយៈការស្នើសុំបញ្ជាក់នេះ រដ្ឋបាលស្រុកកោះកុងបានចេញលិខិតបញ្ជាក់លេខ ១១២/២១ រ.ប.ក ចុះនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ដោយបញ្ជាក់ថា ពិតជាជាស្ថិតនៅក្នុងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ្គ្រីនរិច ពិតប្រាកកដមែន ។ ដោយក្រុមហ៊ុន ហ្គ្រីនរិច បានទទួលសិទ្ធិវិនិយោគលើដីនេះ តាំងពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ មកម្លេះ ។ តាមរយៈលិខិតប្រគល់ទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រវាងភាគីអ្នកលក់ឈ្មោះ [redacted] សេង និងភាគីអ្នកទិញឈ្មោះ [redacted] សារុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ត្រង់ប្រការ១.២ ដូចដែល



Scanned with CamScanner

លោកមេធាវីតំណាងឱ្យដើមចោទ បានលើកឡើងថា ភាគីខាងខ្លួនមិនបានបង់ប្រាក់បង្គ្រប់ ចំនួន ១១២០០០$ (ដប់មួយម៉ឺនពីរពាន់ដុល្លារសហរដ្ឋអាមេរិច) ជូនភាគីដើមចោទនោះ ចំណុចនេះគឺវាមិនអាចធ្វើការបង់ជូនតាមប្រការ១ នៃចំណុច ២ ជូនភាគីដើមចោទបាននោះទេដោយផ្អែកតាមការលើកឡើងរបស់ខ្លួនដូចមានខាងលើ ។ ក្នុងនាមខ្លួនជាមេធាវីតំណាងអាណត្តិឱ្យសហចុងចម្លើយ សូមឱ្យតុលាការលើកចោលនូវពាក្យបណ្ដឹងទាស់របស់ដើមចោទឈ្មោះ[redacted]សេង ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០២២ និងសុំតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២០ ច ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកោះកុង ទាំងមូលទុកជាបានការដដែល ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សេង បានធ្វើសេចក្ដីថ្លែងការណ៍តបថា៖ ខ្លួនសូមធ្វើការច្រានចោលនូវការលើកឡើងរបស់មេធាវីសហចុងចម្លើយ ចោលទាំងស្រុង ចំពោះការលើកឡើងអំពីលិខិតរដ្ឋបាល ដែលភាគីបានលើកឡើងដោយមូលហេតុថា លិខិតមិនទាន់ជាស្ថាពរនៅឡើយ ដែលដីជាដីកម្មសិទ្ធិរបស់ក្រុមហ៊ុន ឬរបស់កូនក្ដីខ្លួននៅឡើយទេ ។ ដោយហេតុថា កូនក្ដីរបស់ខ្លួនកំពុងដោះស្រាយ ករណីនេះនៅសាលាខេត្ត ព្រោះថាដីរបស់ក្រុមហ៊ុន ត្រូវបានកាត់ឆ្វៀលឱ្យប្រជាពលរដ្ឋម្ដងរួចមកហើយ ។ ដោយឡែកក្រុមហ៊ុន ក៏មិនទាន់បង្ហាញនូវឯកសារច្បាស់លាស់នៅសាលាខេត្តនៅឡើយទេ ដូចនេះហើយលិខិតរដ្ឋបាលរបស់ស្រុក មិនទាន់នៅជាផ្លូវការនៅឡើយទេ ។ ចំពោះការលើកឡើងរបស់មេធាវីសហចុងចម្លើយ ថាគាត់មិនអាចអនុវត្តបន្តកិច្ចព្រមព្រៀងនេះ បានតាមចំណុច១.២ មានន័យថា គាត់មិនអនុវត្តតាមកាតព្វកិច្ចទៅហើយ សូមបញ្ជាក់បន្ថែមថា ភាគីទាំងសងខាងពិតជាបានដឹងហើយថា ដីនេះមិនទាន់មានប្លង់កម្មសិទ្ធិនៅឡើយទេ ទើបនៅក្នុងកិច្ចព្រមព្រៀងចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០២១ មិនបានសរសេរឱ្យបានក្បោះក្បាយនោះ ដោយសារតែភាគីត្រូវសហការគ្នា ដើម្បីធ្វើលិខិតផ្ទេរកម្មសិទ្ធិត្រឹមស្រុកជាមួយគ្នា ដូច្នេះហើយចារិកលក្ខណៈ នៃកិច្ចព្រមព្រៀងមាន លក្ខណៈអនុវត្តតាមការអនុវត្តធ្វើជាក់ស្ដែង ។ ជាចុងក្រោយខ្លួន សូមលោកចៅក្រម ទទួលបណ្ដឹងទាស់ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ ទុកជាបានការ និងធ្វើការលុបចោលសាលក្រមរដ្ឋប្បវេណីលេខ ២០ ច ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកោះកុង ដោយចេញសាលក្រមសម្រេចជាថ្មី តាមការទាមទាររបស់ដើមចោទ ដូចមាននៅក្នុងពាក្យបណ្ដឹង ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ៊ួច បានធ្វើសេចក្ដីថ្លែងការណ៍តបថា៖ ខ្លួនសូមធ្វើការបដិសេធសេចក្ដីថ្លែងការណ៍លើកឡើង របស់លោកមេធាវីដើមចោទទាំងស្រុង ដែលបានលើកឡើងថា កូនក្ដីលោកមេធាវី កំពុងតែដោះស្រាយនៅសាលាខេត្ត ពីរឿងកាត់ឆ្វៀលដី ជូនប្រជាពលរដ្ឋ ក៏ដូចជាកូនក្ដីលោកផងដែរ ។ ខ្លួនចង់បញ្ជាក់ជូនថា តាមរយៈលិខិតលេខ ១១២/២១ រ.ប.ក ចុះថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០២១ គឺបានយ៉ាងច្បាស់ រាល់ឯកសារដែលពាក់ព័ន្ធការកាន់កាប់ដី ការទិញលក់ នៅលើទីតាំងដីវិនិយោគរបស់ក្រុមហ៊ុន ហ្វ្រិនវិចគ្រុបនេះ ដោយរដ្ឋបាលស្រុកកោះកុង និងរដ្ឋបាលឃុំជ្រោយប្រស់ ពិតជាមិនអាចចុះហត្ថលេខាទទួលស្គាល់បានឡើយ អ្វីដែលលោកមេធាវី លើកឡើងថា កូនក្ដីលោកពិតជាផ្ទេរសិទ្ធិជូនទៅភាគីអ្នកទិញ ដល់ថ្នាក់ស្រុក នោះមិនអាចទៅរួចទេ យោងទៅតាមការលើឡើងរបស់អាជ្ញាធរខាងលើ និងសុំរក្សានូវការស្នើសុំរបស់ខ្លួន ទុកជាបានការដដែល ។

ខ.ការអះអាងរបស់គូភាគីនៅដំណាក់កាលនៃការទាញហេតុផលផ្ទាល់មាត់៖



Scanned with CamScanner

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សេង បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមរក្សាសេចក្តីថ្លែងការណ៍ ដូចមាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាមទារ ដូចមាននៅក្នុងពាក្យបណ្តឹង រួមមាន៖ ១/សុំរំលាយលិខិតប្រគល់ និងទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រវាងឈ្មោះ [redacted] សេង និងឈ្មោះ [redacted] សារុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ។ ២/រឹបអូសប្រាក់កក់ពីសហចុងចម្លើយឈ្មោះ [redacted] សារុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច នូវទឹកប្រាក់សរុបចំនួន ២៨,០០០$ (ពីរម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិកឱ្យទៅដើមចោទឈ្មោះ [redacted] សេង។ ៣/ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ទុកជាបានការដដែល។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] សារុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមរក្សានៅកំណត់ហេតុនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទុកជាបានការដដែល និងខ្លួនសូមបដិសេធចំពោះការលើកឡើងរបស់លោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទដោយសូមបដិសេធពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ ចោលទាំងស្រុង របស់លោកមេធាវី [redacted] និងសូមបញ្ជាក់អង្គហេតុ ដែលកូនក្តីខ្លួនទិញដីពីឈ្មោះ [redacted] សេង ដែលមានឈ្មោះ [redacted] ប៉ោហេង ជាសាក្សី គឺទិញដីទំហំ ១២ ហិកតា ។ កូនក្តីខ្លួនបានប្រគល់ប្រាក់ជូនភាគីដើមចោទ ចំនួន២៨ ០០០$ (ពីរម៉ឺនប្រាំបីពាន់ដុល្លារសហរដ្ឋអាមេរិច) រួចរាល់ហើយ ប៉ុន្តែនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ នៅពេលដែលកូនក្តីខ្លួន និងភាគីអ្នកលក់ទៅពិនិត្យទីតាំងដី និងបានចុះបានវាស់វែងតាមលិខិតលេខ ០៥៦/២១ ស.ធ.ណ ចុះនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ របស់សាលាស្រុកកោះកុង ពេលចុះទៅដល់ទីតាំងជាក់ស្តែង ទើបដឹងច្បាស់ថាដីខាងលើនេះ គឺពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន [redacted] ។ ទោះបីជាពិនិត្យ និងមើលឃើញយ៉ាងច្បាស់ថា ដីនេះពាក់ព័ន្ធនឹងដីសម្បទាន របស់ក្រុមហ៊ុនក៏ដោយ ក៏ភាគីលោក [redacted] សេង និង លោកស្រី [redacted] ចាន់ សូម៉ាឡា នៅតែអះអាងថាដីខាងលើជាដីរបស់ខ្លួនដដែល ហើយធានាអះអាងថាធ្វើការកាត់ឆ្វៀល និងបំបែកចេញពីអនុក្រឹត្យរបស់រាជរដ្ឋាបាល ដើម្បីធ្វើការកាត់ឈ្មោះឱ្យកូនក្តីខ្លួន ដោយភាគីអ្នកលក់ នៅតែស្នើសុំឱ្យភាគីកូនក្តីខ្លួនបង់ប្រាក់ថ្លៃទិញលក់ ចំនួន ៥០% បន្ថែមទៀត ដើម្បីខ្លួនយកទៅរត់ការកាត់ឈ្មោះជូនមកភាគីសហចុងចម្លើយ ។ ក្រោយមកទៀត ខ្លួនបានដាក់ពាក្យស្នើសុំទៅលោកអភិបាលស្រុកកោះកុង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ដើម្បីដឹងព័ត៌មានពាក់ព័ន្ធដីខាងលើ ឱ្យកាន់តែច្បាស់ ដែលបញ្ជាក់អំពីអត្ថិភាពនៃការកាន់កាប់របស់ឈ្មោះ [redacted] សេង និងលោកស្រី [redacted] ចាន់សូម៉ាឡា លើដីដែលមានទំហំ១២ហិកតា មានទីតាំងស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ។ តើជាដីរបស់ក្រុមហ៊ុន ហ្គ្រីនរិចគ្រុប ឬជាដីរបស់ឈ្មោះ [redacted] សេង និងលោកស្រី [redacted] ចាន់សូម៉ាឡា តាមរយៈការស្នើសុំបញ្ជាក់នេះ រដ្ឋបាលស្រុកកោះកុងបានចេញលិខិតបញ្ជាក់ លេខ ១១២/២១ រ.ប.ក ចុះ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ដោយបញ្ជាក់ថា ពិតជាជាស្ថិតនៅក្នុងដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុន [redacted] ពិតប្រាកកដមែន ។ ដោយក្រុមហ៊ុន [redacted] បានទទួលសិទ្ធិវិនិយោគលើដីនេះ តាំងពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ មកម្លេះ។ តាមរយៈលិខិតប្រគល់ទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រវាងភាគីអ្នកលក់ឈ្មោះ [redacted] សេង និងភាគីអ្នកទិញឈ្មោះ [redacted] សារុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ត្រង់ប្រការ១.២ ដូចដែលលោក មេធាវីតំណាងឱ្យដើមចោទបានលើកឡើងថាភាគីខាងខ្លួនមិនបានបង់ប្រាក់បង្គ្រប់ ចំនួន១១២០០០$ (ដប់មួយម៉ឺនពីរពាន់ដុល្លារសហរដ្ឋអាមេរិច) ជូនភាគីដើមចោទនោះចំណុចនេះ គឺវាមិនអាចធ្វើការបង់ជូន តាមប្រការ១ នៃចំណុច២ ជូនភាគីដើមចោទបាននោះទេ ដោយផ្អែកតាមការលើកឡើង របស់ខ្លួនដូចមានខាងលើនេះ ។ ក្នុងនាមខ្លួន ជាមេធាវីតំណាងអាណត្តិ



Scanned with CamScanner

ឱ្យសហចុងចម្លើយ សូមឱ្យតុលាការលើកចោលនូវ ពាក្យបណ្តឹងទាស់របស់ដើមចោទឈ្មោះ [redacted] សេង ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ និងសុំតម្កល់សាលក្រម រដ្ឋប្បវេណីលេខ ២០ ថ ចុះទី២៤ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកោះកុងទាំងមូល ទុកជាបានការដដែល ។

ខ្លួនបានដាក់ជូនតុលាការពិនិត្យតាមរយៈពាក្យសុំ ជូនភស្តុតាងពិនិត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ តាមរយៈតុលាការ ទុកពេលឱ្យគូភាគី ដាក់ភស្តុតាងរយៈពេល៣សប្តាហ៍ គិតពីថ្ងៃបញ្ចប់នីតិវិធីត្រៀមទាញហេតុផល ។ ភស្តុតាងរួមមាន៖

១. លិខិតប្រគល់ និងទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។

២. លិខិតប្រគល់ និងទទួលប្រាក់កក់លើកទី១ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។

៣. លិខិតលេខ ១១២/២១ រ.ប.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ របស់រដ្ឋបាលស្រុកកោះកុង ។

៤. លិខិតលេខ ១៥៥/០២១ រ.ប.ក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់ឃុំជ្រោយប្រស់ ។

៥. កំណត់ហេតុស្តីពីការចុះពិនិត្យ និងវាស់វែងដីរបស់ឈ្មោះ [redacted] ចាន់សូម៉ាឡា ស្ថិតនៅភូមិជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង បានឃើញ និងឯកភាពដោយ លោក [redacted] ធឿន ។

៦. សេចក្តីជូនដំណឹង ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកោះកុង ។

៧. គំនូសបង្ហាញទីតាំងដីដែលចូលក្នុងក្រុមហ៊ុនប្រ៊ីនរិចគ្រុប

៨. ពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ។

៩. រូបភាពចំនួន១១សន្លឹក ។

សេចក្តីសន្និដ្ឋាន៖

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សេង បានធ្វើសេចក្តីថ្លែងការណ៍តបថា៖ ខ្លួននូវតែអះអាងនៅការច្រានចោលរបស់ភាគីសហចុងចម្លើយដែលរួមមាន៖

១/ សុំរំលាយលិខិតប្រគល់ និងទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រវាងឈ្មោះ [redacted] សេង និងឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច ដោយសារតែការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីសហ ចុងចម្លើយ ។

២/ រឹបអូសប្រាក់កក់ពីសហចុងចម្លើយឈ្មោះ [redacted] សាវុន និងប្រពន្ធឈ្មោះ [redacted] សុខហ្គិច នូវទឹកប្រាក់សរុបចំនួន ២៨,០០០$ (ពីរម៉ឺនប្រាំបីពាន់)ដុល្លារអាមេរិក ឱ្យទៅដើមចោទឈ្មោះ [redacted] សេង ដោយសារភាគីសហចុងចម្លើយ ដោយសារតែមិនអាចអនុវត្តបន្តដោយខ្លួនឯងតាមលិខិតប្រគល់ និងទទួលប្រាក់កក់ ។

៣/ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ដោយសារជាកំហុសរបស់ភាគីសហចុងចម្លើយ ។

ពាក់ព័ន្ធនឹងការលើកឡើងរបស់សហចុងចម្លើយ ដែលបានលើកឡើងថាលិខិតរបស់សាលាស្រុក មិនបញ្ជាក់ថាមិនមែនជាដីរបស់កូនក្តីខ្លួនទេ ម្យ៉ាងមានអនុក្រឹត្យលេខ ២៤៥/ អ.ន.ក្រ ប.ក ចុះនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០២២ ស្តីអំពីការកាត់ឆ្វៀលជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ និងអាស្រ័យផលលើដីរបស់ខ្លួន ។

រហូតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ កូនក្តីរបស់ខ្លួន ក៏បានដាក់ពាក្យស្នើសុំទៅសាលាខេត្ត និងក្រសួងរុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការកាត់ឆ្វៀល ហើយភាគីសហចុងចម្លើយ ក៏បានដឹងដែរថា ដីរបស់កូនក្តីខ្លួនមិនទាន់មានប្លង់រឹងនោះទេ តែអាចធ្វើការកាត់ឆ្វៀលឱ្យគាត់បាន ។ ដោយគាត់បានចុះទៅទីតាំងជាក់ស្តែង បែរជាគាត់បានឈប់ទិញ



Scanned with CamScanner

វិញ ជាការរំលោភនូវកាតព្វកិច្ចត្រង់ចំណុចប្រការ ១.២ នៃលិខិតប្រគល់ និងទទួលប្រាក់កក់ ។ គាត់មិនព្រមឱ្យកូនក្តីខ្លួនរត់ការដើម្បីបញ្ជាក់បានថា កូនក្តីខ្លួនអាចរត់ការទៅសាលាខេត្តដើម្បីកាត់ឆ្វៀលបាន ។ សូមឱ្យ លោកចៅក្រម សម្រេចតាមការស្នើសុំរបស់ខ្លួន និងរក្សានូវការទាមទារដដែល ។ ចំពោះលិខិតរដ្ឋបាលស្រុក គ្រាន់តែជាការជូនដំណឹងទៅឱ្យសហចុងចម្លើយតែប៉ុណ្ណោះ សម្រាប់ការសម្រេច និងការកាត់ឆ្វៀល គឺថ្នាក់ខេត្តជាអ្នកសម្រេចតែប៉ុណ្ណោះ ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] សារុន និងប្រពន្ធឈ្មោះ [redacted] សុខហ៊្គិច បានធ្វើសេចក្តីថ្លែងការណ៍តបថា៖ ខ្លួននៅតែសុំបដិសេធនៅសេចក្តីថ្លែងការណ៍ ដែលលោកមេធាវីដើមចោទបានលើកឡើងចោលទាំងស្រុង លោកមេធាវីនូវតែអះអាងថាកូនក្តីរបស់គាត់ស្នើសុំទៅសាលាខេត្ត និងក្រសួងកសិកម្ម ដើម្បីដំណើរការកាត់ឆ្វៀលដីជូនកូនក្តីរបស់គាត់ជាម្ចាស់កម្មសិទ្ធិ ។ ខ្លួនបាទសូមបញ្ជាក់ថាលិខិត ១១២/២១ រ.ប.ក ចុះនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ គឺបានបញ្ជាក់យ៉ាងច្បាស់ រាល់ឯកសារពាក់ព័ន្ធការកាន់កាប់នូវលើការវិនិយោគ របស់ក្រុមហ៊ុន [redacted] នេះ រដ្ឋបាលស្រុកកោះកុង បានបញ្ជាក់ថា ក្រុមហ៊ុន [redacted] បានទទួលសិទ្ធិវិនិយោគលើដីនេះ តាំងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ មកម្លេះ ។ រាល់ឯកសារដែលពាក់ព័ន្ធការទិញលក់ នៅលើទីតាំងដីវិនិយោគរបស់ក្រុមហ៊ុននេះ រដ្ឋបាលស្រុកកោះកុង និងរដ្ឋបាលឃុំជ្រោយប្រស់ ពិតជាមិនចុះហត្ថលេខាទទួលស្គាល់បានឡើយ ដោយមូលហេតុនេះហើយ លោកមេធាវីបានលើកឡើងថា កូនក្តីខ្លួនមិនបានបំពេញកាតព្វកិច្ចបង់ប្រាក់ ដំណាក់កាលទី២ ទៅភាគីកូនក្តីរបស់លោក គឺកូនក្តីខ្លួនពុំបានរំលោភលើកាតព្វកិច្ចបង់ប្រាក់នោះទេ ដោយភាគីកូនក្តីលោកមិនអាចបំពេញកាតព្វកិច្ចកាត់ផ្ទេរដីខាងលើនោះ មកឱ្យកូនក្តីខ្លួនជាម្ចាស់កម្មសិទ្ធិបានឡើយ យោងតាមដីដែលឈ្មោះ [redacted] សេង បានលក់នោះជាដីរបស់ក្រុមហ៊ុន ។ ដូចនេះស្នើសុំឱ្យតុលាការ សម្រេចតាមការទាមទារ ដោយលើកចោលនូវពាក្យបណ្តឹងទាស់របស់ដើមចោទឈ្មោះ [redacted] សេង ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ និងសុំតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២០ ច ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកោះកុង ទាំងមូលទុកជាបានការដដែល ។

## II.ការពិនិត្យភស្តុតាង

- តុលាការបានធ្វើការពិនិត្យឯកសារភស្តុតាងចំពោះមុខគូភាគី ។

**ភស្តុតាងជាឯកសាររបស់ដើមចោទ (ច្បាប់ថតចម្លង)**

- លិខិតប្រគល់ និងទទួលប្រាក់កក់ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រវាងដើមចោទឈ្មោះ [redacted] សេង និងសហចុងចម្លើយឈ្មោះ [redacted] សារុន ប្រពន្ធឈ្មោះ [redacted] សុខហ៊្គិច ចុះ ចំនួន ០១ច្បាប់ ។

- លិខិតរដ្ឋបាលលេខ: ០៩៦/២១ ស.ជ.ណ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ របស់លោកអភិបាលស្រុកកោះកុង ចំនួន ០១ច្បាប់ ។

- លិខិតជូនដំណឹងលេខ: ១៥២/០២១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ របស់លោកមេឃុំជ្រោយប្រស់ ចំនួន ០១ច្បាប់ ។

- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សេង ចំនួន ០១ច្បាប់ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] សេង លេខ១៩០១២៥២៦៥ ចំនួន ០១ ច្បាប់។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] សារុន លេខ១៨០០០៧៣៣៣ (០១) និងអត្តសញ្ញាណប័ណ្ណ



Scanned with CamScanner

សញ្ញាតិខ្មែររបស់ឈ្មោះ [redacted] សុខហ្វីច លេខ ១៨០០០៧៣៣២ (០១) ចំនួន ០១ ច្បាប់។

ភស្តុតាងជាឯកសាររបស់ចុងចម្លើយ (ច្បាប់ថតចម្លង)

- លិខិតប្រគល់ និងទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។

- លិខិតប្រគល់ និងទទួលប្រាក់កក់លើកទី១ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។

- លិខិតលេខ ១១២/២១ រ.ប.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ របស់រដ្ឋបាលស្រុកកោះកុង ។

- លិខិតលេខ ១៥៥/០២១ រ.ប.ក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់ឃុំជ្រោយប្រស់ ។

- កំណត់ហេតុស្តីពីការចុះពិនិត្យ និងវាស់វែងដីរបស់ឈ្មោះ [redacted] ចាន់សុម៉ាឡា ស្ថិតនៅភូមិជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង បានឃើញ និងឯកភាពដោយ លោក [redacted] ធឿន ។

- សេចក្តីជូនដំណឹង ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកោះកុង ។

- គំនូសបង្ហាញទីតាំងដីដែលចូលក្នុងក្រុមហ៊ុនហ្វ្រីនរិចគ្រុប

- ពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ។

- រូបភាពចំនួន១១សន្លឹក ។

## សំអាងហេតុ

ក.ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី ដែលមានក្នុងសំណុំរឿង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ ដោយមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ ស្នើសុំឱ្យតុលាការសម្រេចតាមការទាមទាររបស់ខ្លួន ដោយលើកចោលនូវពាក្យបណ្តឹងទាស់របស់ដើមចោទឈ្មោះ [redacted] សេង ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ និងសុំតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២០ ច ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកោះកុង ទាំងមូលទុកជាបានការដដែល ។ គប្បីតុលាការពិនិត្យ និងសម្រេចទៅតាមច្បាប់ ។

ខ.ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍តប របស់មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ ស្នើសុំឱ្យតុលាការ សម្រេចតាមការទាមទាររបស់ខ្លួនទាំងស្រុង ដោយផ្អែកលើភស្តុតាងជាឯកសាររបស់ភាគីសហចុងចម្លើយបានដាក់ជូនមកតុលាការ ។

- បានឃើញ លិខិតប្រគល់ និងទទួលប្រាក់កក់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។

- បានឃើញ លិខិតប្រគល់ និងទទួលប្រាក់កក់លើកទី១ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ។

- បានឃើញ លិខិតលេខ ១១២/២១ រ.ប.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ របស់រដ្ឋបាលស្រុកកោះកុង ។

- បានឃើញ លិខិតលេខ ១៥៥/០២១ រ.ប.ក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ របស់ឃុំជ្រោយប្រស់ ។

- បានឃើញ កំណត់ហេតុស្តីពីការចុះពិនិត្យ និងវាស់វែងដីរបស់ឈ្មោះ [redacted] ចាន់សុម៉ាឡា ស្ថិតនៅភូមិជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង បានឃើញ និងឯកភាពដោយ លោក [redacted] ធឿន ។

- បានឃើញ សេចក្តីជូនដំណឹង ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកោះកុង ។

- បានឃើញ គំនូសបង្ហាញទីតាំងដីដែលចូលក្នុងក្រុមហ៊ុនហ្វ្រីនរិចគ្រុប

- បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ។



Scanned with CamScanner

- បានឃើញ រូបភាពចំនួន១១សន្លឹក ។

គ.ចំពោះការអះអាងរបស់គូភាគី ដែលទាក់ទងទៅនឹងដីទំនាស់ខាងលើ មានទីតាំងស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ជាដីរបស់រដ្ឋ ដែលបានធ្វើសម្បទានសេដ្ឋកិច្ចទៅឱ្យក្រុមហ៊ុន [redacted]គ្រប ធ្វើការវិនិយោគ និងគ្រប់គ្រង ។ ដោយភាគីខាងដើមចោទ បានធ្វើការទាមទារ និងអះអាងថាជាដីកម្មសិទ្ធិរបស់ខ្លួន គឺមិនមានឯកសារបញ្ជាក់អំពីចរិតលក្ខណៈនៃការកាន់កាប់ ថាជាដីកម្មសិទ្ធិរបស់ខ្លួន ពិតប្រាកដនោះឡើយ ។ ម្យ៉ាងវិញទៀត ចំពោះទីតាំងដីខាងលើ ក៏មានលិខិត ១១២/២១ រ.ប.ក ចុះនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ របស់រដ្ឋបាលស្រុកកោះកុង បានបញ្ជាក់យ៉ាងច្បាស់ថា ក្រុមហ៊ុន[redacted] បានទទួលសិទ្ធិវិនិយោគលើដីនេះ តាំងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ មកម្ល៉េះ ។ ដូច្នេះការទាមទារដីទំនាស់ខាងលើ ពុំមានលក្ខណៈត្រឹមត្រូវនោះទេ គប្បីតុលាការពិនិត្យ និងសម្រេចទៅតាមច្បាប់ ។

## សេចក្តីសម្រេចបញ្ចប់

១. ទទួលបណ្តឹងទាស់លើ សាលក្រមរដ្ឋប្បវេណីលេខ ២០ ច ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកោះកុង ។

២. ច្រានចោលនូវការទាមទាររបស់ដើមចោទ ដូចដែលមាននៅក្នុងពាក្យបណ្តឹង ចុះនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ។

៣. ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ និងពន្ធលើពាក្យបណ្តឹងដែលបានបង់រួច ត្រូវរឹបអូស ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ នៅវេលាម៉ោង០៣ និង២០នាទីរសៀល និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ នៅវេលាម៉ោង១០ និង០០នាទីព្រឹក កំបាំងមុខដើមចោទ, ចាត់ទុកចំពោះមុខអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ,ចាត់ទុកចំពោះមុខអ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ និងកំបាំងមុខសហចុងចម្លើយ ។

-គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**ក្រឡាបញ្ជី**
**ហត្ថលេខា និងត្រា**
[redacted]

**ចៅក្រម**
**ហត្ថលេខា និងត្រា**
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
កោះកុង ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]



Scanned with CamScanner